# ២កូរិនថូស ៤ មូលដ្ឋានគ្រឹះបេសកកម្មតាមព្រះគម្ពីរ

គ្រូអធិប្បាយ សាស្ត្រាចារ្យ ដន ខាសុន (Don Carson)

តើអ្វីគឺជាមូលដ្ឋានគ្រឹះបេសកកម្មតាមព្រះគម្ពីរ តើយើងគួរតែឆ្លើយនឹងសំនួរនេះយ៉ាងដូចម្តេច? តាមរបៀបមួយយើងអាចមើលទៅលើរឿងនៅក្នុងព្រះគម្ពីរ។ ព្រះបានបង្កើតរបស់សព្វសារពើល្អ។ បន្ទាប់មក មនុស្សបានបះបោរ ហើយយើងអានសេចក្តីសន្យារបស់ព្រះនៅក្នុងលោកុប្បត្តិ ៣:១៥ ឃើញថា ទ្រង់នឹងកិនក្បាលរបស់សត្វពស់។ នៅត្រង់ចំនុចនោះព្រះអាចបំផ្លាញមនុស្សជាតិទាំងមូលបាន ប៉ុន្តែផ្ទុយទៅវិញ ទ្រង់បានសន្យាអំពីសេចក្តីប្រោសលោះដល់មនុស្សវិញ។

បន្ទាប់មក សេចក្តីសំអប់ និងការថ្វាយបង្គំរូបព្រះរីកចម្រើនឡើង ហើយព្រះអាច បំផ្លាញមនុស្សទាំងអស់នៅពេលមានទឹកជំនន់ ប៉ុន្តែព្រះបានសង្គ្រោះមនុស្សចំនួនប្រាំបីនាក់។ បន្ទាប់មក ព្រះបង្កើតមនុស្សជាតិថ្មីមួយតាមរយៈអ័ប្រាហាំ។

ទោះបីជាអ័ប្រាហាំគឺជាមិត្តម្នាក់របស់ព្រះក៏ដោយ ក៏គាត់គឺជាមនុស្សកុហកលើសពីម្តងដែរ ហើយពូជពង្សរបស់គាត់ ក៏មិនមែនជាមនុស្សល្អជាងគាត់ដែរ។ កូនម្នាក់របស់គាត់បានគេងជាស្រីស្នំរបស់ឳពុករបស់ខ្លួន កូនដប់នាក់របស់យ៉ាកុបបានព្យាយាមសំរេចចិត្តសម្លាប់ប្អូនប្រុសរបស់ពួកគេឈ្មោះថា យ៉ូសែប ឬក៏លក់គាត់ឲ្យទៅធ្វើជាទាសករ។ ប៉ុន្តែ ព្រះបានរក្សាពួកគេ ដោយព្រោះពួកគេគឺជាគ្រួសារដែលព្រះបានសន្យាជាមួយ ហើយព្រះបានសន្យាថា ពូជពង្សមួយរបស់យូដានឹងឡើងធ្វើជាស្តេចហើយនឹងប្រោសលោះប្រជារាស្ត្ររបស់ព្រះ (លោកុប្បត្តិ ៤៩)។

កណ្ឌនិក្ខមនំបង្ហាញអំពីសេចក្តីវិនិច្ឆ័យ និងសេចក្តីមេត្តាករុណា នៅពេលព្រះធ្វើឲ្យអ៊ីស្រាអែលក្លាយទៅជាជាតិសាសន៍មួយ។ នៅពេលព្រះប្រទានក្រឹត្យវិន័យ នោះទ្រង់បង្កើតប្រពៃណី ដែលទាយអំពីអ្វីដែលនឹងមកដល់នៅថ្ងៃអនាគត។ ជាឧទាហរណ៍ យញ្ញបូជាដែលថ្វាយនៅថ្ងៃធួននឹងបាប ដែលសម្រាប់អំពើបាបរបស់បណ្តាជន ត្រូវបានធ្វើជារៀងរាល់ឆ្នាំ។

បន្ទាប់មកអំពើបាបរបស់ជនជាតិអ៊ីស្រាអែលបានរីកចម្រើនឡើង ហើយត្រូវបានកត់ត្រាទុកនៅក្នុងកណ្ឌចៅហ្វាយ។ នៅចុងបញ្ចប់កណ្ឌពួកចៅហ្វាយ ស្ថានភាពគឺអាក្រក់ណាស់ គឺពិបាកដឹងថា អ្នកណាជាមនុស្សល្អ និងអ្នកណាជាមនុស្សអាក្រក់។ កណ្ឌចៅហ្វាយបញ្ចប់ដោយបង្ហាញប្រាប់ថា ពួកគេត្រូវការស្តេចមួយអង្គ ពីព្រោះមនុស្សទាំងឡាយតែងប្រព្រឹត្តការអ្វីដែលគេយល់ឃើញថាត្រឹមត្រូវ។

ក្រោយមក ព្រះលើកដាវីឌ ដែលជាមនុស្សតាមបំណងព្រះហឫទ័យព្រះ។ ប៉ុន្តែ ដាវីឌ គឺជាមនុស្សកំផិត និងឃាតករ។ រាជ្យវង្សរបស់ដាវីឌគ្រប់គ្រងលើអ៊ីស្រាអែលតែពីរជំនាន់ប៉ុណ្ណោះ មុនពេលអ៊ីស្រាអែលត្រូវបាក់បែកជាពីរ។ ជាចុងក្រោយដោយសារតែអំពើបាប សេចក្តីលោភលន់ សេចក្តីយង់ឃ្នងរបស់ពូជអំបូរទាំងដប់នៃអាណាចក្រខាងជើង នោះពួកគេត្រូវបានចាប់យកធ្វើជាឈ្លើយសឹក។ ១៥០ ឆ្នាំក្រោយមកពូជអំបូរខាងត្បូងត្រូវបានចាប់ជាឈ្លើយសឹកម្តង។ បន្ទាប់មក ពួកហោរាសន្យាថា ព្រះនឹងបញ្ជូនអ្នកបំរើម្នាក់ដែលនឹងត្រូវរងរបួសសំរាប់សេចក្តីរំលងរបស់យើង (អេសាយ ៥៣)។ ហោរាអេសាយក៏ប្រកាសនៅក្នុងជំពូក១៩ អំពីពេលវេលាមួយដែលប្រជារាស្ត្ររបស់ព្រះនឹងរួមបញ្ចូលពួកសាសន៍ដទៃផងដែរ។

បន្ទាប់មក នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ព្រះយេស៊ូវយាងមក ហើយយើងអានអំពីសេចក្តីបង្គាប់បេសកកម្មរបស់ព្រះអម្ចាស់ និងការប្រទានព្រះវិញ្ញាណបរិសុទ្ធ ហើយបន្ទាប់មកនៅចុងបញ្ចប់ព្រះគម្ពីរ មាននិមិត្តមួយអំពីមនុស្សប្រុសស្រីដែលមកពីគ្រប់ភាសា ពូជអំបូរ និងជាតិសាសន៍ បានរួមគ្នានៅក្នុងសហគមន៍ដែលបានប្រោសលោះមួយ។

ដូច្នេះ យើងអាចនិយាយបានថា មូលដ្ឋានគ្រឹះបេសកកម្មរបស់គ្រីស្ទបរិស័ទ គឺនៅក្នុងព្រះគម្ពីរទាំងមូល។ ដោយសារព្រះគុណរបស់ព្រះ នោះទ្រង់ស្វែងរកពួកមនុស្សមានបាប ហើយសង្គ្រោះមនុស្សជាច្រើន។ ឬយើងអាចផ្តោតលើអង្គព្រះ

យេស៊ូវផ្ទាល់ អំពីព្រះនាម និងតួនាទីខុសៗគ្នារបស់ទ្រង់។ ទ្រង់គឺជាស្ដេចដែលមានគ្រប់ទាំងអំណាចនៅលើស្ថានសួគ៌ និងផែនដី។ ដូច្នេះ ចូរចេញទៅបង្កើតសិស្សចុះ។ ឬយើងអាចគិតអំពី ព្រះយេស៊ូវគឺជាអ្នកគង្វាលល្អ ហើយដោយព្រោះព្រះអង្គជាអ្នកគង្វាលល្អ ទ្រង់ដាក់ជីវិតរបស់ទ្រង់ចុះដើម្បីចៀមរបស់ទ្រង់។ ទ្រង់គឺជាសម្ដេចសង្ឃដែលថ្វាយយញ្ញបូជាឥតខ្ចោះដល់ព្រះ។ ទ្រង់គឺជាព្រះបន្ទូលរបស់ព្រះ ដែលជាការបើកសំដែងដ៏អស្ចារ្យបំផុតអំពីអង្គទ្រង់ទៅកាន់លោកិយទាំងមូល។ ឬយើងគិតអំពី ការស្ដាប់បង្គាប់របស់ព្រះយេស៊ូវ។ នៅក្នុងសួនច្បារកេតសេម៉ានី ទ្រង់មិនអធិស្ឋានថា «ទូលបង្គំពិតជាចង់សុគត ដោយព្រោះទូលបង្គំស្រលាញ់ពួកមនុស្សមានបាបខ្លាំងណាស់» ទេ ប៉ុន្តែទ្រង់អធិស្ឋានថា «ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើង សូមតាមតែព្រះហឫទ័យទ្រង់វិញ»។ អំណាចដែលបណ្ដាលឲ្យព្រះយេស៊ូវយាងទៅឈើឆ្កាង គឺដំបូងបង្អស់ចេញពីការស្ដាប់បង្គាប់របស់ទ្រង់ចំពោះព្រះវរបិតា។ នៅក្នុងយ៉ូហាន ១៤:៣១ ព្រះយេស៊ូវមានបន្ទូលថា «ខ្ញុំធ្វើតាមបង្គាប់ ព្រះវរបិតាវិញ ដើម្បីឱ្យលោកិយបានដឹងថា ខ្ញុំស្រឡាញ់ ដល់ទ្រង់» ។

ឬយើងអាចគិតអំពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងបេសកកម្មរបស់ព្រះយេស៊ូវ (ដូចជាឈើឆ្កាង ការរស់ឡើងវិញ និងការយាងត្រឡប់មកជាលើកទីពីរ ដែលគ្រប់ទាំងជង្គង់ត្រូវលត់ចុះនៅចំពោះទ្រង់) ហើយនិងការអនុវត្តចេញពីព្រឹត្តិការណ៍ទាំងនោះសំរាប់មូលដ្ឋានគ្រឹះបេសកកម្មតាមព្រះគម្ពីរ។

ប៉ុន្តែ របៀបមួយផ្សេងទៀតដែលជួយយើងឲ្យយល់អំពីមូលដ្ឋានគ្រឹះបេសកកម្មតាមព្រះគម្ពីរ គឺដោយការផ្ដោតលើបទគម្ពីរជាក់លាក់មួយ។ យើងអាចមើលលើបទគម្ពីរជាច្រើន ប៉ុន្តែខ្ញុំនឹងមើលលើ២កូរិនថូស ៤:១-១២។

តើបទគម្ពីរនេះជួយយើងឲ្យយល់អំពីមូលដ្ឋានគ្រឹះតាមព្រះគម្ពីរសំរាប់បេសកកម្មយ៉ាងដូចម្ដេច? ខ. ១ និយាយថា « ដូច្នេះ ដែលមានការងារនេះ នោះយើងខ្ញុំមិនណាយចិត្តឡើយ» ។ យោងតាមខ. ២ លោកប៉ុលបរិយាយអំពីព័ន្ធកិច្ចរបស់គាត់ដោយនិយាយថា «យើងខ្ញុំ...សំដែងសេចក្ដីពិត»។ នៅក្នុងខ.៤ លោកប៉ុលសរសេរថា ព័ន្ធកិច្ចនេះទាក់ទងនឹងការប្រកាសថា «ពន្លឺនៃដំណឹងល្អ ដែលសំដែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ»។ យោងតាមខ. ៧-៨...នៅពេលយើងធ្វើមុខងារនេះ យើងគ្រាន់តែជាភាជនៈដីប៉ុណ្ណោះ ប៉ុន្តែយើងទទួលសិរីល្អដែលនៅអស់កល្បជានិច្ចវិញ (ខ. ១៧) ដោយព្រោះយើងសម្លឹងទៅឯអ្វីដែលមើលមិនឃើញ ប៉ុន្តែនៅអស់កល្បជានិច្ច។

និយាយតាមពាក្យផ្សេង ខទាំងនេះមិន*ផ្ដល់អត្ថន័យ*លើបេសកកម្មពិភពលោកនោះទេ ប៉ុន្តែ*បរិយាយ*អំពីវាច្រើនជាង។ ពេលខ្លះ ការបរិយាយរបស់ព្រះគម្ពីរអំពីបេសកកម្ម បានផ្ដល់មូលដ្ឋានគ្រឹះដែលមានអំណាច និងប្រសិទ្ធិភាពបំផុត។ វានឹងមានប្រយោជន៍ដែលយើងមើលលើផ្នែកទាំងបីនៃការបរិយាយនេះ។

### ១. ការងារបម្រើដំណឹងល្អទាមទារឲ្យមានសេចក្ដីសុចរិតទាំងស្រុង។

ខ. ១-៣ ចាប់ផ្ដើមដោយពាក្យ «ដូច្នេះ»។ ពាក្យនេះភ្ជាប់ជំពូក៣ជាមួយនឹងខទាំងនេះ។ នៅក្នុង២កូរិនថូស ៣ ប៉ុលបង្រៀនថា ការងាររបស់គាត់ជាសាវ័កម្នាក់មានផលប្រយោជន៍ច្រើនជាងការងាររបស់ម៉ូសេ ដែលម៉ូសេមាននៅពេលដែលព្រះប្រទានក្រឹត្យវិន័យ។ និយាយតាមពាក្យផ្សេង ការងាររបស់សម្ព័ន្ធមេត្រីថ្មីដែលបោះត្រាដោយលោហិតរបស់ព្រះយេស៊ូវ គឺធំប្រសើរជាងការងាររបស់សម្ព័ន្ធមេត្រីចាស់។ ដូច្នេះ យើងអាននៅក្នុង៣:៤-៦ «ហើយយើងមានសេចក្ដីសង្ឃឹមយ៉ាងនោះដល់ព្រះ ដោយសារព្រះគ្រីស្ទ មិនមែនថា យើងខ្ញុំពូកែល្មមដោយខ្លួនឯង នឹងគិតស្មានថា មានអ្វីកើតពីខ្លួនយើងខ្ញុំនោះឡើយ តែដែលយើងខ្ញុំពូកែ នោះមកតែពីព្រះទេ ដែលទ្រង់បានប្រោសឱ្យយើងខ្ញុំអាចនឹងធ្វើជាអ្នកបំរើនៃសញ្ញាថ្មីបាន មិនមែនតាមតែន័យពាក្យប៉ុណ្ណោះទេ គឺតាមព្រះវិញ្ញាណវិញ ដ្បិតន័យពាក្យ នោះធ្វើឱ្យស្លាប់ តែព្រះវិញ្ញាណ ទ្រង់ប្រទានឱ្យ

មានជីវិតវិញ»។ ចូរកត់សំគាល់អំពីភាពផ្ទុយគ្នារវាងសម្ព័ន្ធមេត្រីទាំងពីរ។ នៅក្នុងខ.៧-៩ «ហើយបើការងារខាងឯសេចក្តីស្លាប់(ក្រិត្យវិន័យ) ដែលបានឆ្លាក់ជាអក្សរលើថ្ម (ក្រិត្យទាំង១០ប្រការ) បានកើតមកក្នុងសិរីល្អ ដល់ម្ល៉េះបានជាជនជាតិអ៊ីស្រាអែល មិនអាចនឹងសំឡឹងមើលមុខលោកម៉ូសេបានទេ ដោយព្រោះសិរីល្អនៃមុខលោក គឺជាសេចក្តីដែលកំពុងតែសូន្យបាត់ទៅ នោះចំណង់បើការងារខាងឯព្រះវិញ្ញាណ តើនឹងមានសិរីល្អលើសជាងអម្បាលម៉ានទៅ ដ្បិតបើសិនជាការងារខាងឯសេចក្តីកាត់ទោស មានសិរីល្អទៅហើយ នោះការងារខាងឯសេចក្តីសុចរិត ប្រាកដជានឹងមានសិរីល្អជាបរិបូរលើសទៅទៀត»។ ឬម្តងទៀតនៅក្នុងខ.១៨ «ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ»។

ដូច្នេះ (ខ.១) ដែលមានការងារនេះ នោះយើងខ្ញុំមិនណាយចិត្តឡើយ ថ្វីបើការងាររបស់សម្ព័ន្ធមេត្រីថ្មីមានឯកសិទ្ធិជាច្រើនក៏ដោយ ក៏អាចមានហេតុផលជាច្រើនដែលនាំឲ្យអស់កម្លាំងចិត្ត និងការធ្លាក់ទឹកចិត្តយ៉ាងខ្លាំងផងដែរ ប៉ុន្តែដោយសារយើងមានការងារនេះតាមរយៈសេចក្តីមេត្តាករុណារបស់ព្រះ ដូចដែលជំពូក៣បានបង្ហាញ នោះយើងមិនអស់កម្លាំងចិត្តនោះទេ។ មុននឹងយើងពិភាក្សាបន្តទៅទៀត យើងគួរតែសួរសំនួរពីរសិន។

ទីមួយ តើការលើកឡើងអំពីការងារនេះសំដៅតែទៅលើការងាររបស់ពួកសាវ័កឬ? បើដូច្នោះ យើងគួរតែប្រយ័ត្នអំពីការអនុវត្តការលើកឡើងនេះមកកាន់យើងនិងការងារបេសកកម្មពិភពលោកនៅសព្វថ្ងៃនេះ។ ប៉ុន្តែ ទោះបើជំពូក៣ផ្តោតលើប៉ុលនិងការងាររបស់ពួកសាវ័កក៏ដោយ ក៏នៅចុងបញ្ចប់ជំពូក៣រហូតដល់ជំពូក៤និង៥ លោកប៉ុលបានយកសេចក្តីពិតអំពីការងាររបស់ពួកសាវកមកអនុវត្តចំពោះការងាររបស់គ្រីស្ទបរិស័ទទាំងអស់។ យើងមើលឃើញការនេះនៅក្នុង៣:១៨ ដែលថា «*ហើយយើងរាល់គ្នាទាំងអស់*ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ទាំងមុខទទេ» ហើយនៅក្នុង ៥:៩-១០ «ហេតុនោះបានជាយើងខ្ញុំសង្វាត ឱ្យបានគាប់ដល់ព្រះហឫទ័យទ្រង់ ទោះនៅក្នុងរូបកាយ ឬឃ្លាតពីរូបកាយក្តី ដ្បិត*យើងទាំងអស់គ្នា*ត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ»។

សំនួរទីពីរគឺ «តើការធ្លាក់ទឹកចិត្តអ្វីដែលលោកប៉ុលមាន? បើសិនជាគាត់មានគ្រប់ទាំងឯកសិទ្ធិជារបស់សម្ព័ន្ធមេត្រីថ្មីនេះ តើហេតុអ្វីលោកប៉ុលត្រូវល្បួងឲ្យអស់កំឡាំងចិត្ត?»

ទីមួយ មនុស្សជាច្រើនមិនពេញចិត្តទេ នៅពេលយើងប្រកាសសេចក្តីពិតរបស់ព្រះគម្ពីរយ៉ាងច្បាស់ (ខ. ២)។ នេះជាមូលហេតុប៉ុលសរសេរក្នុងខ.២ថា «យើងខ្ញុំលះចោលអស់ទាំងការលាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ គឺយើងខ្ញុំផ្ទុកផ្តាក់ខ្លួន និងបញ្ញាចិត្តរបស់មនុស្សទាំងអស់ នៅចំពោះព្រះ ដោយសំដែងសេចក្តីពិតវិញ »។ តើហេតុអ្វីមានមនុស្សប្រើឧបាយកល? ពីព្រោះសេចក្តីបង្រៀនខ្លះ ដែលព្រះគម្ពីរមាន មិនមានប្រជាប្រិយភាព។ លើសពីនេះ មនុស្សជាច្រើនដើរតាមវប្បធម៌របស់ពួកគេយ៉ាងល្ងង់ ហើយព្រះនៃលោកិយនេះបានធ្វើឲ្យភ្នែករបស់ពួកគេងងឹតចំពោះដំណឹងល្អ។ ជាឧទាហរណ៍ ប្រសិនបើអ្នកនិយាយថា ព្រះយេស៊ូវគឺជាផ្លូវតែមួយទៅស្ថានសួគ៌ នោះមនុស្សជាច្រើនមិនចូលចិត្តអ្វីដែលអ្នកនិយាយនេះទេ ពីព្រោះពួកគេគិតថា អ្នកជាមនុស្សម្នាក់ដែលឆ្កួតនឹងសាសនានិងមានចិត្តចង្អៀតចង្អល់។ ដូច្នេះ តើយើងឆ្លើយតបយ៉ាងដូចម្តេច? តើយើងគ្រាន់តែនិយាយថា «មនុស្សគ្រប់គ្នាមានសេចក្តីជំនឿផ្ទាល់ខ្លួនរបស់ពួកគេ ហើយប្រហែលជាមានផ្លូវផ្សេងៗទៀតទៅកាន់ព្រះ?»។ ប្រហែលលោកពេត្រុសមិនកំពុងប្រាប់សេចក្តីពិតនៅក្នុងកិច្ចការ ៤:១២ នៅពេលគាត់បាននិយាយថា «គ្មានសេចក្តីសង្គ្រោះដោយសារអ្នកណា ទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀត បានប្រទានមកមនុស្សលោក ឱ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ។ ប្រហែលជាព្រះ

យេស៊ូវកំពុងមានបន្ទូលបំផ្លើសហើយមើលទៅ នៅពេលទ្រង់បានមានបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»។ ទាំងនេះគឺជាសេចក្តីថ្លែងដែលតូចចង្អៀតរបស់មនុស្សដែលឆ្កួតនឹងសាសនា»។ តើយើងឆ្លើយបែបនេះឬ? ទេ! ការដែលមនុស្សបដិសេធសេចក្តីពិតទាំងនេះដែលមកពីព្រះគម្ពីរជាភស្តុតាងថា ព្រះនៃសម័យនេះបានធ្វើឲ្យគំនិតរបស់ពួកអ្នកមិនជឿបានងងឹត។ ជារឿយៗមនុស្សមិនគិតថាខ្លួនពួកគេមានទោសនោះទេ ប៉ុន្តែគិតថាជាអ្នករងគ្រោះដោយសារអ្នកដទៃវិញ ប៉ុន្តែយើងមិនអាចយល់អំពីការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងបានច្បាស់លាស់នោះទេ បើយើងគ្រាន់តែចង់បានព្រះអង្គសង្គ្រោះមួយអង្គដែលសង្គ្រោះយើងចេញពីលទ្ធផលនៃអំពើបាបរបស់អ្នកដទៃនោះ។ មនុស្សជាច្រើនមិនចង់ជឿអំពីស្ថាននរកទេ ប៉ុន្តែអ្នកនៅក្នុងព្រះគម្ពីរដែលនិយាយអំពីស្ថាននរកច្រើនបំផុតនោះគឺជា ព្រះយេស៊ូវ។ អ្នកមិនអាចស្មោះត្រង់ចំពោះព្រះយេស៊ូវដោយមិននិយាយអ្វីសោះអំពីស្ថាននរកនោះទេ។ និយាយក្នុងពាក្យផ្សេង ពេលខ្លះមនុស្សមិនពេញចិត្តនឹងសេចក្តីពិត។ ព្រះយេស៊ូវបានជ្រាបអំពីការនេះនៅក្នុងសម័យរបស់ទ្រង់។ នៅក្នុងយ៉ូហាន ៨:៤៥ ព្រះយេស៊ូវមានបន្ទូលថា «ដោយព្រោះតែខ្ញុំនិយាយសេចក្តីពិត បានជាអ្នករាល់គ្នាមិនជឿខ្ញុំ»។ ប្រសិនបើព្រះយេស៊ូវបានមានបន្ទូលថា «ទោះបើខ្ញុំប្រាប់សេចក្តីពិតដល់អ្នក នោះអ្នកមិនជឿទេ» នោះការមិនជឿរបស់ពួកគេអាក្រក់ហើយ ប៉ុន្តែនោះមិនមែនជាអ្វីដែលព្រះយេស៊ូវបានមានបន្ទូលនោះទេ។ ព្រះយេស៊ូវបានមានបន្ទូលថា «*ដោយព្រោះតែ*ខ្ញុំនិយាយសេចក្តីពិត បានជាអ្នករាល់គ្នាមិនជឿខ្ញុំ»។ ដូច្នេះ សេចក្តីមិនជឿរបស់ពួកគេកាន់តែអាក្រក់ទៅ។ ប្រសិនបើនេះគឺជារបៀបដែលមនុស្សឆ្លើយតបចំពោះសេចក្តីពិត នោះតើអ្វីដែលយើងអាចធ្វើបាន? និយាយកុហកដើម្បីឲ្យមនុស្សនឹងជឿឬ? ប្រសិនបើយើងធ្វើដូចនេះ នោះតើពួកគេជឿលើអ្វី? ពួកគេជឿលើសេចក្តីកំភូតហើយ។ ដូច្នេះ វាអាចជាការធ្លាក់ទឹកចិត្តយ៉ាងខ្លាំងក្នុងការអធិប្បាយសេចក្តីពិត ហើយមើលឃើញថា មនុស្សមិនគ្រាន់តែបដិសេធសេចក្តីពិតប៉ុណ្ណោះ ប៉ុន្តែពួកគេក៏បដិសេធអ្នក ដោយថាអ្នកជាមនុស្សឆ្កួតនឹងសាសនាផងដែរ។ ប្រសិនបើអ្នកអានអក្សរសាស្ត្ររបស់អ្នកដែលមានសាសនាដទៃនៅក្នុងសតវត្សទី៣គ.ស ការរិះគន់សាមញ្ញបំផុតរបស់អ្នកមានសាសនាដទៃប្រឆាំងនឹងជំនឿគ្រីស្ទបរិស័ទគឺ ជំនឿគ្រីស្ទបរិស័ទមានគំនិតតូចចង្អៀត ដាច់ដោយឡែកពីគេ និងឆ្កួតនឹងសាសនាខ្លាំងពេក។

គ្រីស្ទបរិស័ទខ្លះអាចមានអារម្មណ៍ថា ពួកគេគឺជាវីរបុរស នៅពេលព្រះបានហៅពួកគេមកបម្រើព្រះគ្រីស្ទ និងបម្រើដំណឹងល្អ ប៉ុន្តែបន្ទាប់មកយើងដឹងថា ការបម្រើនេះ គឺពិបាក ឬគ្រោះថ្នាក់ទៀតផង។ សូម្បីតែប៉ុល ក៏ត្រូវល្បួងឲ្យអស់កម្លាំងចិត្តដែរ។ ប៉ុន្តែ គាត់និយាយថា «ដូច្នេះ ដែលមានការងារនេះ (ដែលមានសិរីល្អលើសជាង) នោះយើងខ្ញុំមិនណាយចិត្តឡើយ តាមខ្នាតនៃសេចក្តីមេត្តាករុណា ដែលយើងខ្ញុំទទួលមក»។ ដូច្នេះ «យើងខ្ញុំលះចោលអស់ទាំងការលាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ គឺយើងខ្ញុំផ្ទុកផ្តាក់ខ្លួន និងបញ្ញាចិត្តរបស់មនុស្សទាំងអស់នៅចំពោះព្រះ ដោយសំដែងសេចក្តីពិតវិញបើសិនណាជាដំណឹងល្អរបស់យើងខ្ញុំត្រូវគ្របបាំង នោះគឺត្រូវគ្របបាំងចំពោះតែពួកអ្នក ដែលកំពុងវិនាសទេ»។

នៅកន្លែងផ្សេងទៀតប៉ុលប្រឈមនឹងសេចក្តីល្បួងផ្សេងៗទៀត។ នៅក្នុង២:១៧ ប៉ុលសរសេរថា «ដ្បិតយើងខ្ញុំមិនមែនដូចជាមនុស្សច្រើនគ្នា ដែលបំប្លែងព្រះបន្ទូលនោះទេ គឺដូចជាអ្នកស្មោះត្រង់ ដែលមកពីព្រះវិញ ហើយយើងនិយាយចំពោះព្រះដោយនូវព្រះគ្រីស្ទ»។ អ្នកខ្លះនឹងអធិប្បាយព្រះបន្ទូលព្រះដើម្បីបង្កើនប្រាក់ចំណូល។ ប៉ុលបានជួបនិងបដិសេធសេចក្តីល្បួងនេះ។ បន្ទាប់មកគាត់ជួបសេចក្តីល្បួង ខុសគ្នាមួយទៀតនៅក្នុង ១១:២០-២១ «ពីព្រោះអ្នករាល់គ្នា ទ្រាំទ្រនឹងការដែលគេចាប់អ្នកប្រើ ឬបើអ្នកណាទះកំផ្លៀងអ្នកនោះផង ខ្ញុំនិយាយបែបជាបន្ទាបខ្លួន ទុកដូចជាយើងខ្ញុំខ្សោយមែន»។ គ្រីស្ទបរិស័ទខ្លះស្វែងរកពួកអ្នកដឹកនាំដែលខ្លាំង ហើយប្រព្រឹត្តបែបនេះ។ ប៉ុន្តែ តើការដឹកនាំបែបនេះបង្កើតចារិកលក្ខណៈ និង

ការបន្ទាបខ្លួនដូចព្រះគ្រីស្ទដែរឬទេ? វាមិនបង្កើតបានទេ ដូច្នេះប៉ុលមិនដឹកនាំដូច្នេះទេ គឺគាត់និយាយផ្ទុយថា «យើងខ្ញុំខ្សោយមែន» (១១:២១)។ លោកប៉ុលបានតាំងចិត្តមិនប្រើឧបាយកល មិនធ្វើឲ្យព្រះបន្ទូលខូច មិនលក់ព្រះបន្ទូលដើម្បីប្រាក់ មិនបង្កើនប្រាក់ចំណូលដោយការប្តូរសេចក្តីពិតទៅជាអ្វីដែលមនុស្សចង់ស្តាប់ឮនោះឡើយ។ ប៉ុន្តែ គាត់ផ្ទុកផ្តាក់ខ្លួន និងបញ្ញាចិត្តរបស់មនុស្សទាំងអស់ នៅចំពោះព្រះ ដោយសំដែងសេចក្តីពិតវិញ។

យើងត្រូវការសេចក្តីក្លាហាន។ អាទិភាពរបស់យើងត្រូវតែជាការចុះចូលចំពោះព្រះបន្ទូលរបស់ព្រះ។ ដូច្នេះ ប្រសិនបើអ្នកចង់ដឹងថា អ្វីគឺជាបេសកកម្មពិភពលោកតាមព្រះគម្ពីរនោះចូលស្តាប់ប្រយោគមួយនេះ យើងត្រូវបម្រើដំណឹងល្អដោយជីវិតសុចរិតនិងស្មោះត្រង់។

២. ដំណឹងល្អសំដែងបង្ហាញអំពីសិរីល្អរបស់ព្រះគ្រីស្ទ (ខ. ៣-៦)។

កាតព្វកិច្ចរបស់យើង គឺត្រូវតែប្រកាសដំណឹងល្អ បើទោះជាមនុស្សមិនអាចមើលឃើញពន្លឺរបស់ដំណឹងល្អក៏ដោយ ខ. ៤ «ជាពួកអ្នក ដែលព្រះរបស់លោកិយនេះ បានបង្អាប់ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសំដែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ បានភ្លឺមកដល់គេ»។ តើដំណឹងល្អបង្ហាញអំពីអ្វី? សិរីល្អរបស់ព្រះគ្រីស្ទដ៏ជារូបអង្គព្រះ (ខ. ៤)។ បន្ទាប់មកក្នុងខ. ៥ «យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ គឺពីព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់វិញ»។

តើយើងអាចដឹងថា ព្រះមានលក្ខណៈបែបណា បើគ្មាននរណាម្នាក់អាចមើលឃើញព្រះនោះទេ? ចម្លើយគឺ ត្រូវសិក្សាអំពីព្រះយេស៊ូវ។ កណ្ឌហេព្រើរនិយាយថាព្រះយេស៊ូវគឺជា «រស្មីភ្លឺមកពីសិរីល្អនៃព្រះហើយជារូបភាពនៃអង្គទ្រង់»។ ដំណឹងល្អគឺអំពីព្រះយេស៊ូវ និងថាទ្រង់ជានរណា ទ្រង់គឺជាអ្នកតំណាងរបស់ព្រះពិតប្រាកដ ទ្រង់ គឺជាព្រះអម្ចាស់ដែលបានរស់ពីសុគតឡើងវិញ ដែលព្រះវរបិតាបានទទួលយកយញ្ញបូជារបស់ទ្រង់។ ទោះបើទ្រង់បានបន្ទាបខ្លួន ដោយហេតុនេះបានជាព្រះបានលើកទ្រង់យ៉ាងខ្ពស់ ហើយបានប្រទានអោយមាននាមដ៏ប្រសើរលើសជាង អស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះអោយគ្រប់ ទាំងជង្គង់នៅស្ថានសួគ៌នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ។ ដូច្នេះ យើងមិនកំពុងនិយាយអំពីព្រះយេស៊ូវដែលអ្នកប្រើ (ទូលអង្វរ) ព្រះនាមរបស់ទ្រង់ ហើយសេចក្តីអធិស្ឋានទាំងអស់របស់អ្នកត្រូវបានឆ្លើយតបនោះទេ។ យើងកំពុងប្រកាសព្រះ ដែលបានត្រឡប់ជាសាច់ឈាម ត្រូវគេឆ្កាង និងរស់ពីសុគតឡើងវិញ ត្រូវបានរំដោះឲ្យរួចពីទោស និងមានអធិបតីភាពលើគ្រប់ទាំងអស់ ដើម្បីឲ្យទ្រង់ទទួលបានអំណាចទាំងអស់របស់ព្រះ និងដើម្បីឲ្យគ្រប់ទាំងជង្គង់នឹងលុតចុះនៅចំពោះទ្រង់នៅថ្ងៃចុងក្រោយ។

សំនួរមួយដ៏ល្អគឺ «តើដំណឹងល្អគឺអ្វី?»។ ដំណឹងល្អគឺជាដំណឹង។ ដំណឹងល្អគឺជាដំណឹងដែលមានអំណាច។ តើអ្នកធ្វើអ្វីចំពោះដំណឹង? អ្នកប្រកាសដំណឹងល្អ។ ប៉ុន្តែ នេះមិនមែនជាដំណឹងធម្មតានោះទេ វាគឺជាដំណឹងអំពីព្រះយេស៊ូវ អំពីទ្រង់ជានរណា និងអ្វីដែលទ្រង់បានធ្វើតាមបញ្ញត្តិរបស់ព្រះផ្ទាល់ ជាពិសេសឈើឆ្កាង ការរស់ពីសុគតឡើងវិញ និងការលើកឡើងទៅស្ថានសួគ៌របស់ទ្រង់ ដើម្បីប្រោសលោះមនុស្សមួយចំនួនសំរាប់អង្គទ្រង់ ចេញពីគ្រប់ពូជអំបូរ និងភាសា និងជាតិសាសន៍ ហើយបង្កើតសហគមន៍ថ្មីនេះ ដែលទិញដោយលោហិតរបស់ព្រះគ្រីស្ទ គឺពួកជំនុំរបស់ព្រះដ៏មានព្រះជន្មរស់ រហូតដល់មនុស្សទាំងអស់ដែលបានប្រោសលោះមកឯទ្រង់ នៅក្នុងស្ថានសួគ៌ថ្មីនិងផែនដីថ្មី។ នេះគឺជាដំណឹងល្អ។ ដំណឹងល្អមិនមែន «ជឿ» នោះទេ។ នេះគឺជាការអនុវត្តរបស់ដំណឹងល្អដែលយើងចាំបាច់ត្រូវធ្វើ។ ដំណឹងល្អមិនមែន «ចាប់ផ្តើមជីវិតថ្មីដោយប្រែចិត្ត» នោះទេ បើទោះជាយើងត្រូវតែប្រែចិត្តក៏ដោយ។ អ្វីដែលយើងប្រកាសគឺជាអ្វីដែលព្រះបានធ្វើតាមរយៈព្រះគ្រីស្ទ ហេតុនេះហើយបានជាមានការផ្តោតខ្លាំងលើព័ន្ធកិច្ចអធិប្បាយនិងប្រកាស។ យើងប្រកាសអំពីព្រះយេស៊ូវជាព្រះ

អម្ចាស់ ដោយមូលហេតុនេះ យើងគឺជាអ្នកបំរើរបស់បងប្អូនព្រោះតែព្រះយេស៊ូវ (៤:៥)។ ការផ្លាស់ប្រែ ការស្ដាប់បង្គាប់ មនុស្សដែលរីករាយក្នុងការដើរតាមព្រះ គឺជាផលផ្លែរបស់ដំណឹងល្អ ប៉ុន្តែអ្វីដែលយើងអធិប្បាយជាអាទិភាព អ្វីដែលយើងប្រកាសជាដំណឹង គឺជាព្រះយេស៊ូវគ្រីស្ទ ដែលគេបានឆ្កាង ទ្រង់ជានរណា អ្វីដែលទ្រង់បានធ្វើ ជាពិសេសនៅក្នុងការសុគត និងការរស់ឡើងវិញរបស់ទ្រង់ ក្នុងការប្រោសលោះមនុស្សមួយចំនួនសំរាប់អង្គទ្រង់។ ទ្រង់បានផ្ទុកអំពើបាបរបស់យើងនៅក្នុងរូបកាយរបស់ទ្រង់ផ្ទាល់ ដើម្បីឲ្យយើងបានរាប់ជាសុចរិតនៅក្នុងទ្រង់។

ដូច្នេះ ប្រសិនបើយើងបានមកឃើញពន្លឺនៃដំណឹងល្អ គឺដោយព្រោះព្រះជាម្ចាស់ «ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឱ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ»(ខ.៦)។ ដូច្នេះ ប្រសិនបើយើងបានមកឃើញសេចក្តីពិត នោះមិនដោយសារយើងឆ្លាតជាងនោះទេ ប៉ុន្តែដោយសារ*ព្រះជាម្ចាស់ «ទ្រង់*បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឱ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ»។

ប៉ុលនិយាយដល់ការបង្កបង្កើតដែលព្រះបានមានបន្ទូលថា «ចូរឲ្យមានពន្លឺ»។ ភាពងងឹតមិនអាចបញ្ឈប់ពន្លឺបានទេ។ និយាយតាមពាក្យផ្សេង យើងប្រកាសដំណឹងល្អ ប៉ុន្តែគ្រប់ទាំងការប្រែចិត្តគឺជាលទ្ធផលដែលព្រះមានបន្ទូលម្តងទៀតថា «ចូរឲ្យមានពន្លឺ» «ចូរឲ្យមានពន្លឺចេញពីភាពងងឹត» ហើយព្រះមានអំណាចប្រទានជីវិតថ្មីដល់យើង។ ប្រសិនបើព្រះមិនធ្វើការនេះទេ នោះភាពងងឹតនៅតែបន្តមានដដែល។ មនុស្សឆ្លាតអាចស្តាប់ឮព្រះបន្ទូលរបស់ព្រះ ហើយនៅតែស្ថិតក្នុងភាពងងឹតដដែល រហូតដល់ព្រះមានបន្ទូលថា «ចូរឲ្យមានពន្លឺ»។

នៅពេលខ្ញុំអធិប្បាយដំណឹងល្អនេះ ដែលសំដែងពីសិរីល្អនៃព្រះគ្រីស្ទ ទំនុកចិត្តរបស់ខ្ញុំមិនមែនថា មនុស្សនឹងចាប់អារម្មណ៍ពាក្យសំដី និងរបៀបវៃឆ្លាតរបស់ខ្ញុំក្នុងការអធិប្បាយដំណឹងល្អនោះទេ ប៉ុន្តែទំនុកចិត្តរបស់ខ្ញុំគឺ ម្តងហើយម្តងទៀតព្រះនឹងមានបន្ទូលថា «ចូរឲ្យមានពន្លឺ» ហើយមនុស្សខ្វាក់អាចមើលឃើញបាន។ ពន្លឺរបស់ទ្រង់នឹងបញ្ចាំងនៅក្នុងចិត្តរបស់មនុស្សកាន់តែច្រើន ដើម្បីឲ្យពួកគេបានមើលឃើញសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ។

ប្រសិនបើអ្នកចង់ដឹងថា មូលដ្ឋានគ្រឹះបេសកកម្មតាមព្រះគម្ពីរមានលក្ខណៈយ៉ាងដូចម្តេច នោះសូមមើលប្រយោគនេះ *ដំណឹងល្អបង្ហាញអំពីសិរីល្អរបស់ព្រះគ្រីស្ទ*។

៣. ដើម្បីបម្រើដំណឹងល្អ យើងផ្ទុកសេចក្តីស្លាប់ និងមានព្រះជន្មរបស់ព្រះគ្រីស្ទនៅក្នុងរូបកាយ។ នេះគឺជាគំនិតនៅក្នុងខ. ៧-១២។

ដំណឹងល្អគឺជាទ្រព្យសម្បត្តិដ៏អស្ចារ្យ ជាអំណាចដ៏ អស្ចារ្យដែលអាចផ្លាស់ប្រែមនុស្សដែលងងឹតខាងព្រលឹងវិញ្ញាណបាន។ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឱ្យឥទ្ធិឫទ្ធិដ៏លើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ។ ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្តីវិលវល់ តែមិនទ័លគំនិតទេ មានគេធ្វើទុក្ខ តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្លុក តែមិនស្លាប់ទេ។

ប្រសិនបើយើងអានរហូតដល់២កូរិនថូស ១១ នោះប៉ុលរំលឹកយើងអំពីទុក្ខលំបាកខ្លះដែលគាត់បានជួបប្រទះសំរាប់ប្រយោជន៍ដំណឹងល្អ។ គាត់បានលិចសំពៅចំនួនបីដង ដែលនេះនៅមុនគាត់លិចសំពៅនៅក្នុងកិច្ចការ ២៧។ ចំនួនប្រាំដងគាត់បានត្រូវគេវាយនឹងរំពាត់៤០ខ្វះ១ (១១:២៤) ចំនួនបីដងពួករ៉ូម៉ាំងបានវាយគាត់បីដំបង (១១:២៥) ក្រៅពីគ្រោះថ្នាក់ទាំងអស់ដែលគាត់លើកឡើង ជារឿយៗគាត់ឃ្លាន ហើយគាត់ក៏លើកឡើងអំពីគ្រោះថ្នាក់ព្រោះតែបងប្អូនក្លែងក្លាយផងដែ

រ។ ដូច្នេះ គាត់និយាយសេចក្តីពិតនៅពេលគាត់និយាយថា យើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្តីវិលវល់មានគេធ្វើទុក្ខ...តែមិនស្លាប់ទេ។

គាត់សង្ខេបទុក្ខលំបាកទាំងអស់នៅក្នុងខ. ១០ ថា «យើងខ្ញុំផ្ទុកសេចក្តីសុគតនៃព្រះអម្ចាស់យេស៊ូវ នៅក្នុងរូបកាយយើងខ្ញុំជានិច្ច ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបកាយយើងខ្ញុំដែរ»។ ខ្ញុំគិតថា នេះគឺជារបៀបមួយផ្សេងទៀតដែលយើងត្រូវតែលីឈើឆ្កាងរបស់យើងហើយដើរតាមព្រះយេស៊ូវ។ យើងត្រូវតែស្លាប់ខាងខ្លួនរបស់យើង។ លោកប៉ុលបានជួបប្រទះស្ថានភាពជាច្រើនដោយព្រោះគាត់បានស្លាប់ខាងខ្លួនរបស់គាត់ ហើយដេញតាមការប្រកាសដំណឹងល្អ និងសរសើរតម្កើងព្រះគ្រីស្ទ។ ប្រសិនបើការស្លាប់ខាងខ្លួនឯងមានន័យថា យើងត្រូវគេសង្កត់សង្កិន និងធ្វើឲ្យវិលវល់ នោះគឺជាអ្វីដែលគាត់ត្រូវតែទ្រាំទ្រ។ ប៉ុន្តែ ចូរកត់សំគាល់ថាមាន «ដើម្បីឱ្យ» នៅពាក់កណ្តាលខ. ១០។ «ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបសាច់យើង ដែលតែងតែស្លាប់នោះ ហេតុនោះបានជាសេចក្តីស្លាប់កំពុងតែចម្រើនឡើងក្នុងយើងខ្ញុំ តែជីវិតចម្រើនក្នុងអ្នករាល់គ្នាវិញ»។

និយាយតាមពាក្យផ្សេង នេះមិនមែនគ្រាន់តែជាការគ្រាស់ហៅមកឯការរងទុក្ខ និងការលះបង់ប៉ុណ្ណោះនោះឡើយ។ ព្រះមិនជំពាក់បំណុលអ្នកណាម្នាក់ឡើយ។ ពាក្យ «ដើម្បីឲ្យ» គឺជាអំណាចនៃដំណឹងល្អ ដែលធ្វើការនៅក្នុងជីវិតរបស់យើង ជីវិត របស់ព្រះគ្រីស្ទធ្វើការនៅក្នុងយើង និងនាំមកនូវសិរីល្អ និងរង្វាន់។ សូមចងចាំអ្វីដែលប៉ុលសរសេរនៅក្នុងជំពូក១២។ គាត់បានកំពុងរងទុក្ខតាមរយៈអ្នកនាំសាររបស់សាតាំង ដែលជាបន្លាដែលព្រះបានប្រទានដល់គាត់។ គាត់អធិស្ឋានសូមព្រះនឹងដោះបន្លានេះចេញ ប៉ុន្តែព្រះមានបន្ទូលថា ទ្រង់នឹងមិនដោះវាចេញឡើយ ប៉ុន្តែទ្រង់នឹងប្រទានព្រះគុណបន្ថែមទៀត រហូតដល់លោកប៉ុលយល់អំពីឧត្តមភាពនៃការទទួលបានកម្លាំងបែបនេះតាមរយៈព្រះគុណ ហើយគាត់និយាយថា «ដូច្នេះខ្ញុំនឹងស៊ូអួតពីសេចក្តីកម្សោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឱ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ»

នៅពេលខ្ញុំនៅក្មេង មានការសង្កត់ធ្ងន់ជាច្រើនអំពីសារៈសំខាន់នៃការលះបង់បំរើព្រះគ្រីស្ទ ប្រយោជន៍ដើម្បីអោយយើងសម្រេចបេសកកម្មរបស់ព្រះគ្រីស្ទ។ យើងត្រូវការស្តាប់ឮការសង្កត់ធ្ងន់ទាំងនោះនៅសព្វថ្ងៃនេះ។ យើងបានច្រៀងចម្រៀងថា «ខ្ញុំ(ព្រះគ្រីស្ទ)បញ្ជូនអ្នកឲ្យធ្វើការដែលគ្មានរង្វាន់ បំរើដោយមិនមានថ្លៃឈ្នួល បម្រើមនុស្សដែលមិនស្រឡាញ់យើង និងមិនស្គាល់ ហើយឲ្យត្រូវគេស្តីបន្ទោស និងរងទុក្ខដោយគេជេរប្រមាថ។ នេះគឺជារបៀបដែលខ្ញុំ (ព្រះគ្រីស្ទ) កំពុងបញ្ជូនអ្នកឲ្យធ្វើការសំរាប់ខ្ញុំ។ នេះគឺជារបៀបដែលខ្ញុំកំពុងបញ្ជូនអ្នកឲ្យរងទុក្ខសំរាប់ជាប្រយោជន៍របស់ខ្ញុំ។ ខ្ញុំកំពុងបញ្ជូនអ្នកទៅរកសេចក្តីឯកា បោះបង់ផ្ទះសំបែង គ្រួសារ និងមិត្ត។ ខ្ញុំកំពុងបញ្ជូនអ្នកឲ្យស្គាល់តែសេចក្តីស្រលាញ់របស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំកំពុងបញ្ជូនអ្នកឲ្យចាកចោលពីមហិច្ឆតាក្នុងជីវិតរបស់អ្នក ឲ្យស្លាប់ខាងសេចក្តីប៉ងប្រាថ្នារបស់អ្នក ឲ្យខិតខំធ្វើការនិងស្រលាញ់កន្លែងណាដែលមនុស្សជេរប្រមាថអ្នក។ ខ្ញុំបញ្ជូនអ្នកឲ្យស្រលាញ់ជីវិតរបស់អ្នកនៅក្នុងខ្ញុំ។ ខ្ញុំ(ព្រះគ្រីស្ទ)កំពុងបញ្ជូនអ្នកទៅឯចិត្តរឹង ពីព្រោះមានសេចក្តីសំអប់ ទៅឯភ្នែកដែលធ្វើងងឹត ពីព្រោះពួកហ្នឹងមើលមិនឃើញ និងឲ្យទៅចំណាយឈាមរបស់អ្នកផង។ ខ្ញុំបញ្ជូនអ្នកឲ្យភ្លក់រស់ជាតិកាល់វ៉ារី។

គ្រប់ការទាំងនេះពិតជាត្រឹមត្រូវ ប៉ុន្តែវាគ្រាន់តែជាសេចក្តីពិតពាក់កណ្តាលប៉ុណ្ណោះ។ ពីព្រោះទោះជាលោកប៉ុលនិយាយថា ខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក ហើយមានសេចក្តីវិលវល់ ហើយមានគេធ្វើទុក្ខ ហើយត្រូវគេវាយដួលស្តូក ក៏គាត់នៅនិយាយក្នុងខ. ១០ ថា «ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបកាយយើងខ្ញុំដែរ»។ គាត់ក៏និយាយនៅក្នុងខ. ១១ ថា «ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបសាច់យើង ដែលតែងតែស្លាប់នោះ»។ គាត់ក៏និយាយនៅក្នុងខ. ១៥ ថា v15 «ពីព្រោះគ្រប់ទាំងអស់សំរាប់អ្នករាល់គ្នា ដើម្បីឱ្យព្រះគុណ ដែលចំរើនឡើង ដោយសារមនុស្សជាច្រើន បានប

ណ្ដាលឱ្យមានសេចក្ដីអរព្រះគុណចំរើនជាបរិបូរឡើង ដល់សិរីល្អនៃព្រះលើសទៅទៀត»។ គាត់ក៏និយាយនៅក្នុង៣:១៨ ថា «ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ»។ ហើយគាត់ក៏និយាយនៅក្នុង៤:១៧-១៨ ថា «ដ្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឱ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ» ផងដែរ។

ការសង្កត់ធ្ងន់ទាំងពីរនេះត្រូវតែនៅជាមួយគ្នា។ យើងត្រូវបានឆ្កាងជាមួយព្រះគ្រីស្ទ ហើយយើងមើលឃើញសិរីល្អជាមួយទ្រង់។ យើងស្លាប់ខាងខ្លួនឯង ហើយយើងមានជីវិតរបស់ទ្រង់កាន់តែច្រើននៅក្នុងជីវិតរបស់យើង។ អ្នកមិនអាចមានមួយហើយអត់មួយនោះឡើយ។ ពួកវានៅជាមួយគ្នា។ អ្នកមិនអង្វរសុំការលះបង់ខ្លួន ពីព្រោះអ្នកគឺជាម្នាក់ដែលរីករាយនៅក្នុងទុក្ខលំបាក។ ព្រះមិនជំពាក់បំណុលរបស់អ្នកណាមួយឡើយ។ ប៉ុន្តែនៅក្នុងការដើរតាមព្រះគ្រីស្ទ ដែលទ្រង់បានយាងទៅឈើឆ្កាង នោះយើងក៏រៀនលីឈើឆ្កាងរបស់យើង ហើយវាក៏ជាផ្នែកមួយនៃបេសកកម្មផងដែរ។ ដូច្នេះ ប្រសិនបើអ្នកចង់ដឹងថា បេសកកម្មតាមព្រះគម្ពីរមានលក្ខណៈយ៉ាងដូចម្ដេច នោះប្រយោគនេះប្រាប់អ្នកហើយ។ ដើម្បីបម្រើដំណឹងល្អ យើងផ្ទុកសេចក្ដីស្លាប់ និងមានព្រះជន្មរបស់ព្រះគ្រីស្ទនៅក្នុងរូបកាយ។ ដូច្នេះ តើមូលដ្ឋានគ្រឹះបេសកកម្មតាមព្រះគម្ពីរគឺជាអ្វី? ខគម្ពីរទាំងនេះមិនផ្ដល់និយមន័យសំរាប់មូលដ្ឋានគ្រឹះបេសកកម្មនោះទេ ប៉ុន្តែពង្រីកនិមិត្តរបស់យើងកាន់តែធំ អំពីរបៀបដែលបេសកកម្មចងភ្ជាប់នឹងដំណឹងល្អ ដែលអនុវត្តដោយសេចក្ដីសុចរិត និងសេចក្ដីស្មោះត្រង់ ដែលពេញដោយការងប់របស់ព្រះក្នុងការ សំដែងសិរីល្អរបស់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដែលប្រកាសតាមរយៈការស្លាប់ខាងខ្លួនឯង ដែលពោរពេញទៅដោយជីវិតរបស់ព្រះគ្រីស្ទដែលផ្លាស់ប្រែយើង។ នេះគឺជាខ្លឹមសារនៃបេសកកម្មតាមព្រះគម្ពីរ។

The above is an abridged translation of "The Biblical Basis for Missions: Treasure in Jars of Clay" by Don Carson. If you wish to hear the original English sermon, please go to http://thegospelcoalition.org/resources/entry/the_biblical_basis_for_missions_treasure_in_jars_of_clay